អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
ការិយាល័យសហព្រះរាជអាជ្ញា
Extraordinary Chambers in the Courts of Cambodia
Office of the Co-Prosecutors

ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៩

# <u>សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិ</u>

ដោយសារចំណាប់អារម្មណ៍របស់សាធារណជន ដែលនៅតែមាននៅក្នុងកិច្ចដំណើរការនីតិវិធី ទាក់ទិននឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា និងដោយអនុលោមតាមវិធាន៥៤ នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាអន្តរជាតិ សូមចេញសេចក្តីប្រកាសព័ត៌មានដូចខាងក្រោម ។

នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់សេចក្តីជូនដំណឹងមួយ ស្តីពីការខ្វែងយោបល់គ្នា ក្នុងចំណោមសហព្រះរាជអាជ្ញា (“ការខ្វែងយោបល់”) ទាក់ទិននឹងភាពសមស្របនៃការបើកកិច្ចស៊ើបសួរថ្មីប្រឆាំងនឹងជនសង្ស័យបន្ថែមទៀតចំពោះបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការនៃតុលាការនេះ ។ នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់សេចក្តីថ្លែងការណ៍ជាសារវ័ន្ត ស្តីពីការខ្វែងយោបល់ (“សេចក្តីថ្លែងការណ៍”) ។ នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាជាតិបានដាក់ ចម្លើយតបរបស់ខ្លួនទៅនឹងសេចក្តីថ្លែងការណ៍នេះ ។ អង្គបុរេជំនុំជម្រះ (“អង្គជំនុំជម្រះ”) បានចុះបញ្ជីកិច្ចដំណើរការនីតិវិធីចាប់ពីពេលនោះមកថាជា ការខ្វែងយោបល់គ្នាលេខ ០០១/១៨-១១-២០០៨/អ.វ.ត.ក/អ.ជ.ស.ដ ។

នៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០០៩ អង្គជំនុំជម្រះ បានអញ្ជើញសហព្រះរាជអាជ្ញា ឲ្យដាក់សេចក្តីសន្និដ្ឋានបន្ថែមទៀតឲ្យបានមុនថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការខ្វែងយោបល់គ្នា ប្រសិនជាមាន ។ ដើម្បីជាការឆ្លើយតប នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិ បានជូនដំណឹងដល់អង្គជំនុំជម្រះថា ខ្លួនមិនមានសេចក្តីសន្និដ្ឋានដែលត្រូវធ្វើបន្ថែមពីលើនេះទៀតទេ ។ ចំណែកឯសហព្រះរាជអាជ្ញាជាតិវិញ កាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៩ បានដាក់ឯកសារបន្ថែមមួយចំនួន ។ នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាជាតិ តាមការផ្តួចផ្តើមគំនិតរបស់ខ្លួនផ្ទាល់ បានដាក់ឯកសារបន្ថែមទៀត ។

នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៩ អង្គជំនុំជម្រះបានណែនាំដល់សហព្រះរាជអាជ្ញា ឲ្យធ្វើការឆ្លើយតបដាច់ដោយឡែកពីគ្នា ឲ្យបានមុនថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩ ទៅនឹងសំនួរមួយចំនួនដែលរៀបចំឡើងដោយអង្គ

ជំនុំជម្រះ ស្តីពីការខ្វែងយោបល់គ្នានេះ និងឲ្យដាក់ចម្លើយតបទៅនឹងចម្លើយរបស់គ្នាទៅវិញទៅមក ត្រឹមថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០០៩ ។ អង្គជំនុំជម្រះបានណែនាំថា ប្រសិនបើមានការតម្រូវ សវនាការដោយផ្ទាល់មាត់ គួរតែត្រូវបើកធ្វើនៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៩ ខាងមុខនេះ ។ ប្រសិនបើ សវនាការដោយផ្ទាល់មាត់ត្រូវបាន កំណត់ពេលជាក់លាក់នោះ សហព្រះរាជអាជ្ញាអន្តរជាតិ សុំស្នើទៅអង្គជំនុំជម្រះ យ៉ាងហោចណាស់ឲ្យ បានធ្វើឡើងមានលក្ខណៈសាធារណៈ និងអសាធារណៈខ្លះ ៕

- ចប់ -